ក                N°21/15→19/3/2015

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៧-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៥៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី ហួប៊ីន** (LI HUABIN) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តហឺប៉ី សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្តូរឈ្មោះជា **លី រ៉ូប៊ឺត** ( LI ROBERT) ២៤១៨

២៧-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៥៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចាំង លូជឺ** (ZHANG LUZE) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តសានតុង សាធារណរដ្ឋប្រជាមានិតចិន ២៤១៩

០២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/១៨០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ខាង វ៉ីមីង** (KANG WEIMING) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ២៤២០

០២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/១៨១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **តាំ ក្វុកឈឹង** (TAM KWOK CHEUNG) ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ២៤២១

០២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/១៨២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឈាវ ប៉ៃជួ** (CHIOU PAI-JUI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតនៅទីក្រុងតៃប៉ិ សាធារណរដ្ឋចិន ២៤២២

០២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/១៨៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជាចង្កោមគ្រួសារ ដល់គ្រួសារលោក **ថាង យីហ្គាង** ដែលមានសមាជិក :

១- លោក **ថាង យីហ្គាង** (TANG YIGANG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ថាង ហ្គោដុន** (TANG GORDON) (ជាប្តី)

២- អ្នកស្រី **ចិន ហួយដាន** (CHEN HUAIDAN) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ថាង សិលីន** (TANG CELINE) (ជាប្រពន្ធ) ២៤២៣

១២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២០០ ស្ដីពី ការតែងតាំងឯកឧត្ដម **ឌី នរិទ្ធ** ជាប្រធាន នៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ សម្រាប់អាណត្តិបន្ត ២៤២៤
១២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២០១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧកញ៉ា លោកជំទាវ អស់លោក និងលោកស្រី ចំនួន ១៣ រូប ២៤២៥
១២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២០២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កីឡាការិនី ចំនួន ០២ រូប ២៤២៦
១៦-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២០៤ ស្ដីពី ការតែងតាំងឯកឧត្ដម **សំបូរ វណ្ណារិទ្ធ** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ២៤២៧

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

១០-៣-២០១៥ -អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្ដីពី ឯកសណ្ឋាន និងប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ២៤២៨
១១-៣-២០១៥ -អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្ដីពី ការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ២៤៤៧
១២-៣-២០១៥ -អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្ដីពី ការកាត់ផ្ទៃដីទំហំ ៣១៥,១ ហិកតា នៅស្រុកស្វាយលើ ខេត្តសៀមរាប ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លីឈួង សំណង់ និងអាហារ័ណនីហារ័ណ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤៥២
១២-៣-២០១៥ -អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្ដីពី ការកាត់ផ្ទៃដីទំហំ ២.២១៦,៧៣ ហិកតា នៅស្រុកវ៉ារិន ខេត្តសៀមរាប ចេញពីដីព្រៃសម្បទានសំរោងវូឌ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ផលប្រយោជន៍សាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤៥៥

១២-៣-២០១៥ -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១៦៨,៥០ ហិកតា នៅស្រុក វ៉ារិន ខេត្តសៀមរាប ចេញពីដីដែលមានដីកាដកហូតលេខ ១២៩ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក មួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤៥៨

១២-៣-២០១៥ -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៥៤៦,៦៤ ហិកតា នៅស្រុកវ៉ារិន ខេត្តសៀមរាប ក្នុងនោះកាត់ចេញពីដីគម្របព្រៃឈើ ២០០២ និងកាត់ចេញពីដីព្រៃសម្បទានក្រុមហ៊ុន សំរោង វូឌ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤៦១

១២-៣-២០១៥ -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.០៦២,៩៦ ហិកតា នៅស្រុកវ៉ារិន ខេត្តសៀមរាប ក្នុងនោះកាត់ចេញពីដីដែលមានដីកាដកហូតលេខ ១២៩ និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់សហគមន៍ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ២៤៦៤

០៦-៣-២០១៥ -អនុក្រឹត្យលេខ ២៦៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ២៤៦៧

០៦-៣-២០១៥ -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៤៦៩

០៩-៣-២០១៥ -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ២៤៧៤

០៩-៣-២០១៥ -អនុក្រឹត្យលេខ ២៦៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៤៧៨

០៩-៣-២០១៥ -អនុក្រឹត្យលេខ ២៧០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ២៤៨៨

០៩-៣-២០១៥ -អនុក្រឹត្យលេខ ២៧១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៤៩៤

០៩-៣-២០១៥ -អនុក្រឹត្យលេខ ២៧២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៤៩៥

០៩-៣-២០១៥ -អនុក្រឹត្យលេខ ២៧៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៤៩៦

១០-៣-២០១៥ -អនុក្រឹត្យលេខ ២៧៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៤៩៧

១០-៣-២០១៥ -អនុក្រឹត្យលេខ ២៧៥ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែង និងតែងតាំងមន្ត្រីរាជការ ២៤៩៨

១០-៣-២០១៥ -អនុក្រឹត្យលេខ ២៧៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង មន្ត្រីនគរបាលជាតិកម្ពុជា ២៤៩៩

## ២-សេចក្តីសម្រេច


១១-៣-២០១៥ -សេចក្តីសម្រេចលេខ ១៥ សសរ ស្តីពី ការកែសម្រួលប្រការ ៣ នៃសេចក្តីសម្រេចលេខ ២៨ សសរ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពី ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ២៥០០

១២-៣-២០១៥ -សេចក្តីសម្រេចលេខ ១៦ សសរ ស្តីពី ការបង្កើតអនុគណៈកម្មការជំនួយការ នៃគណៈកម្មាធិការរៀបចំកិច្ចប្រជុំបូកសរុប ដកពិសោធន៍សកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ២៥០២

១៣-៣-២០១៥ -សេចក្តីសម្រេចលេខ ១៧ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ២៥០៦


## ៣-សារាចរ


១៨-៣-២០១៥ -សារាចរលេខ ០២ សរ ស្តីពី ការបើកផ្តល់បៀវត្សសម្រាប់ខែមេសា ឆ្នាំ ២០១៥ និងប្រាក់ឧបត្ថម្ភក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិ ឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩ ២៥០៧


# III-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ


២៣-០២-២០១៥ -ប្រកាសលេខ ០៦១/១៥ កប/ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២៥០៩

២៣-០២-២០១៥ -ប្រកាសលេខ ០៦២/១៥ កប/ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានព័ត៌មានទីផ្សារការងារ ២៥១៣

២៣-០២-២០១៥ -ប្រកាសលេខ ០៦៣/១៥ កប/ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបណ្តុះបណ្តាល ២៥២០

២៣-០២-២០១៥ -ប្រកាសលេខ ០៦៤/១៥ កប/ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា ២៥២៩


## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៥៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជេនី គ្លូប៊ល ណេតវើក** ២៥៣៨

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៥៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេតី ខនស្ត្រាក់សិន & ដេគ័រ** ២៥៤០

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៥៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេស៊ា អ៊ិនវេីទេធីវ ឌីវេឡុបម៉ិន** ២៥៤២

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៦៧ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **សេនធ័រ ហ្វរ អ៊ិនជូឆាយណា មីសិន** ២៥៤៤

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ីុង រួយ (ខេមបូឌា)** ២៥៤៦

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេស៊ី អេនធើប្រាយ (ខេមបូឌា) លីមីធីត** ២៥៤៨

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៧០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខារ៉េលីន អ៊ីហ្គ័រ អ៊ិនវេសម៉ិន** ២៥៥០

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៧១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អង្គរមាស (កម្ពុជា)** ២៥៥២

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៧២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេមបូឌាន បើម៉ូ ហ្វូម ថេកស្តាយ** ២៥៥៤

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ហួប៊ីន** (LI HUABIN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៨៥ នៅខេត្តហឺប៉ី សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្តូរឈ្មោះជា **លី រ៉ូប៊ើត** (LI ROBERT)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល-១៥០២-១៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៥

លេខ: ១៦៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាំង លូជឺ** (ZHANG LUZE) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៦៩ នៅខេត្តសានតុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១៥០២.១៥៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: ១៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី០៤ ខែ មិនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/១៨០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ខាង វ៉ីមីង** (KANG WEIMING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦១ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៥០៣.១៨១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥*

លេខ:១៧៦៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/១៧១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **តាំ ឃុកឆឹង** (TAM KWOK CHEUNG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៦៥ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៥០៣.១៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥

លេខ:១៧៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៣ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៣១៥/១៨៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈាវ ប៉ៃជុ** (CHIOU PAI-JUI) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៨២ នៅទីក្រុងតៃប៉ិ សាធារណរដ្ឋចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៩.១៥០៣.១៨៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៥*

លេខ: ១៧៦.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៤ ខែ ៣ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៣១៥/១៨៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មជាចង្កោមគ្រួសារ ដល់គ្រួសារលោក **ថាង យីហ្គាង** ដែលមានសមាជិក:

១- លោក **ថាង យីហ្គាង** (TANG YIGANG) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៦៧ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ថាង ហ្គោដុន** (TANG GORDON) (ជាប្តី)។

២- អ្នកស្រី **ជិន ហួយដាន** (CHEN HUAIDAN) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៦៧ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ថាង សិលីន** (TANG CELINE) (ជាប្រពន្ធ)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧-១៥០៣-១៨៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥*

លេខ: ១៧៤.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២០០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៩ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ទី នរិន្ទ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** សម្រាប់អាណត្តិបន្ត ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរល.១៥០៣.២០១

លេខៈ ៧១៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២០១

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ**

| | | | | | |
|---|---|---|---|---|---|
| ១- ឧកញ៉ា | **សុខ** | **វណ្ណា** | ៣- ឧកញ៉ា | **ឡៅ** | **ចេងហេង** |
| ២- ឧកញ៉ា | **ហួយ** | **ចាយសេង** | | | |

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- លោក | **សុខ** | **យាក** | ៤- លោក | **ស្វាយ** | **វុឌ្ឍី** |
| ២- ឧកញ៉ា | **សុខ** | **ហុង** | ៥- លោកជំទាវ | **ពេជ្រ** | **សុខឡូត** |
| ៣- ឧកញ៉ា | **មាស** | **ម៉ូរីយ៉ា** | | | |

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- លោក | **ឃីម** | **សុធី** | ៤- លោក | **សាយ** | **សុភ័ក្រា** |
| ២- លោកជំទាវ | **ស៊ាន** | **ណារី** | ៥- លោកជំទាវ | **សុខ** | **ចន្ទូ** |
| ៣- លោកស្រី | **សុខ** | **ចន្ទី** | | | |

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១២ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រល.១៥០៣.២០២

លេខៈ ៤៦៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២០២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**
កីឡាការិនី **កែ ឡេង**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**
កីឡាការិនី **អ៊ុក ស្រីមុំ**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វព្រះរាជហឫទ័យ**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរល.១៥០៣.២០៣

លេខៈ ៤១៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **សំបូរ វណ្ណារិទ្ធ** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៧រសរ.១៥០៣.២០៥

លេខៈ ២២០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ/.

- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់នូវឯកសណ្ឋាន សញ្ញាសក្តិ មួក សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ សម្រាប់ប្រើប្រាស់បំពេញការងារចុះអនុវត្តច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងច្បាប់ស្តីពីផ្លូវថ្នល់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អធិការកិច្ចផ្លូវថ្នល់ សរសេរជាអក្សរកាត់ថា **អ.ក.ផ.ថ.**។

## ជំពូកទី២
## ឯកសណ្ឋាន សញ្ញាសក្តិ និងមួក
### ផ្នែកទី១
### ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវបានកំណត់ជា២(ពីរ)ថ្នាក់ ដូចខាងក្រោម៖

១- ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យនិងមន្ត្រីផ្សេងទៀត។

**ក- ឯកសណ្ឋានបុរស**

- អាវដៃខ្លីពណ៌កាគី កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ជីបចង្កេះ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរផ្នត់ ប៉ះផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ និងឡេវមានត្រារូបព្រះស[illegible]

- អាវដៃវែងពណ៌កាគី កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ជីបភ្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ហារពណ៌មាសពីក្រោមហូតដល់លើ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានជីបភ្លីចំនួនពីរ និងមានឆែកចំកណ្តាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌សដៃវែង ក្រវាត់កពណ៌លឿងចាស់ សម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌កាគី ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខពីរ មានហោប៉ៅចំនួនបីហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

**ខ- ឯកសណ្ឋាននារី**

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌កាគី ឬសំពត់ហ៊្វីបពណ៌កាគី សម្រុងក្រោមជង្គង់ ឆែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

រូបគំរូនៃឯកសណ្ឋាននេះ មានដូចក្នុងឧបសម្ព័ន្ធទី១។

២- ថ្នាក់ភ្នាក់ងារ។

**ក. ឯកសណ្ឋានបុរស**

- អាវដៃខ្លីពណ៌កាគី កឌុប ថ្នេរឌុប ចោះឡេវចុងក ប៉ូលស្មាសងខាង ហោប៉ៅពីរដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ ហើយឡេវពីមុខនិងឡេវហោប៉ៅមានពណ៌ដូចអាវ
- អាវដៃវែងពណ៌កាគី កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ជីបភ្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ហារពណ៌ប្រាក់ពីក្រោមហូតដល់លើ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់ កណ្តាលមានគម្រប រាងចតុកោណកែង ផ្នែកខាងក្រោយមានជីបភ្លីចំនួនពីរ និងមានឆែកចំកណ្តាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌ផ្ទៃមេឃដៃវែង ក្រវាត់កពណ៌លឿងចាស់សម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌កាគី ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

**ខ. ឯកសណ្ឋាននារី**

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌កាគី ឬសំពត់ហ្សីបពណ៌កាគីកាត់ក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ។

## ផ្នែកទី២
## សញ្ញាសក្តិ

**មាត្រា៣ .-**

សញ្ញាសក្តិស្មា ត្រូវមានបាតក្រោមប្រវែង៦(ប្រាំមួយ)សង់ទីម៉ែត្រ បណ្តោយពីលើបាតក្រោមប្រវែង១៣(ដប់បី)សង់ទីម៉ែត្រ និងមានទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៧សង់ទីម៉ែត្រ មានរាងកោងជាមុំទាល។

សញ្ញាសក្តិស្មា ត្រូវបានរៀបចំជា៨(ប្រាំបី)ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់អគ្គនាយក ថ្នាក់អគ្គនាយករង ថ្នាក់ប្រធាននាយកដ្ឋាន ថ្នាក់អនុប្រធាននាយកដ្ឋាន ថ្នាក់ប្រធានការិយាល័យ ថ្នាក់អនុប្រធានការិយាល័យ ថ្នាក់មន្ត្រី ថ្នាក់ភ្នាក់ងារះ

**១- ថ្នាក់អគ្គនាយក :** មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ **"អ.ក.ផ.ថ."** ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំធំទ្រខាងក្រោម មានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល និងមានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី២។

**២- ថ្នាក់អគ្គនាយករង :** មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ **"អ.ក.ផ.ថ."** ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំតូចទ្រខាងក្រោម មានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល និងមានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៣។

**៣- ថ្នាក់ប្រធាននាយកដ្ឋាន :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំធំ នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ក.ផ.ថ."** ពណ៌មាស នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូល នៅចំកណ្តាលមានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញហើយមានខ្សែពួរវេញ៣(បី)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៤។

**៤- ថ្នាក់អនុប្រធាននាយកដ្ឋាន :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ក.ផ.ថ."**ពណ៌មាស នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ២(ពីរ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៥។

៥- **ថ្នាក់ប្រធានការិយាល័យ :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ក.ផ.ថ."** ពណ៌មាស នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញហើយមានខ្សែពួរវេញ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៦។

៦- **ថ្នាក់អនុប្រធានការិយាល័យ :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ក.ផ.ថ."** ពណ៌ប្រាក់ នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ១(មួយ) ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៧។

៧- **ថ្នាក់មន្ត្រី :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ក.ផ.ថ."** ពណ៌ប្រាក់ នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌ប្រាក់នៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៨។

៨- **ថ្នាក់ភ្នាក់ងារ :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ក.ផ.ថ."** ពណ៌ប្រាក់ នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌ប្រាក់ នៅខាងចុងនៃសញ្ញាសក្តិមានក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ១(មួយ)ខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៩។

## ផ្នែកទី៣

## មួក

**មាត្រា៤ ._**

មួកកាស្កេត ត្រូវបានរៀបចំជា៦(ប្រាំមួយ)ថ្នាក់៖

១- **ថ្នាក់អគ្គនាយក :** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសដល់ជើងមួក និងខាងក្រោមក្បាច់មានប៉ាក់វណ្ណពួរពណ៌មាសពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ ព្រមទាំងនៅខាងចុងខ្សែវណ្ណទាំងពីរខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្វែងក្របីធំដល់ជើងមួក។

២- **ថ្នាក់អគ្គនាយករង :** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានប៉ាក់វណ្ណពួរពណ៌មាសពីក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ ព្រម...

ខាងចុង ខ្សែវណ្ណទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

៣- **ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន :** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានកណ្តាប់វណ្ណពណ៌មាសនៅពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាសនៅខាងចុងកម្រង ខ្សែសយទាំងពីរខាងមានភ្ជាប់ឡេវព្រះសង្ការពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

៤- **ប្រធានការិយាល័យ អនុប្រធានការិយាល័យ :** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណ ដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ការពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីដោយ ចុងសងខាងទុកចន្លោះ៤(បួន)ស.ម. ពីជើងមួក។

៥- **ថ្នាក់មន្ត្រី :** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ការពណ៌មាស។ នៅលើក្បាំងមួកគ្មានប៉ានក្បាច់ភ្ញីទេសទេ។

៦- **ថ្នាក់ភ្នាក់ងារ :** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ការពណ៌ប្រាក់។ នៅលើក្បាំងមួកគ្មានប៉ានក្បាច់ភ្ញីទេសទេ។ រូបគំរូនៃមួកខាងលើនេះ មានដូចក្នុងឧបសម្ព័ន្ធទី១០។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៥ ..**

សញ្ញាពាក់នៅលើដៃអាវខាងស្តាំ ជាសញ្ញានិមិត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ធ្វើអំពីក្រណាត់សំពត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម.។

**មាត្រា៦ ..**

សញ្ញាសម្គាល់របស់អធិការកិច្ចផ្លូវថ្នល់មានរាងមូលប៉ោងទំហំ៤,៧ស.ម. ធ្វើអំពីស្ពាន់ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ពាក់នៅលើហោប៉ៅអាវស្តាំ។

សញ្ញាសម្គាល់រួមមានសញ្ញានិមិត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ដែលព័ទ្ធជុំវិញដោយពាក់កណ្តាលខាងលើជាអក្សរខ្មែរ "អធិការកិច្ចផ្លូវថ្នល់" និងពាក់កណ្តាលខាងក្រោមជាអក្សរអង់គ្លេស "Inspector of Roads"។

**មាត្រា៧ ..**

សញ្ញាសម្រាប់ប៉ាក់ជាប់ចុងកអាវរបស់អធិការកិច្ចផ្លូវថ្នល់ ជាសញ្ញានិមិត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

**មាត្រា៨ ..**

ស្លាកសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងដែលមានបណ្តោយប្រវែង៩,៥ស.ម. ទទឹង២,០ស.ម. ដែលសរសេរអក្សរពណ៌ទឹកមាស និងពាសដោយជ័រវីងថ្លាមានផ្ទៃពណ៌ខ្មៅ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញ ដែលមានទំហំ០,១៥ស.ម.។ ប៉ែកខាងស្តាំដៃនៃស្លាកឈ្មោះមានសញ្ញានិមិត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ និងប៉ែកខាងឆ្វេងមានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមានអត្តលេខរបស់មន្ត្រីរាជការ។

**មាត្រា៩ ..**

ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ដល់មន្ត្រីម្នាក់ៗចំនួន២(ពីរ)កំប្លេ នូវឯកសណ្ឋានខ្លីឬវែង សម្រាប់ប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ។

## ជំពូកទី៤
## បណ្ណសម្គាល់ខ្លួន

**មាត្រា១០ ..**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវមានបណ្ណសម្គាល់ខ្លួនដើម្បីបញ្ជាក់អត្តសញ្ញាណក្នុងពេលបំពេញភារកិច្ច ដែលចេញដោយសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

បណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវមានអត្តលេខ ឈ្មោះ បិទរូបថត ចុះហត្ថលេខា និងបោះត្រាជាផ្លូវការរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

**មាត្រា១១ ..**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ មួក សញ្ញាសម្គាល់ បណ្ណសម្គាល់ខ្លួន និងលិខិតបញ្ជាបេសកកម្ម ឬលិខិតឧទ្ទេសនាម ក្នុងពេលបំពេញបេសកកម្ម។ ក្នុងពិធីប្រជុំឬពិធីការផ្សេងៗទៀត បើចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ ដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា១២ ..**

ជនណាក្លែងបន្លំ ដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិឬសញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០. ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ.៥៨...អនក្រ.បក.........ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### ឯកសណ្ឋានសម្រាប់បំពេញបេសកកម្ម



## ឯកសណ្ឋានសម្រាប់ចូលរួមពិធីប្រជុំឬពិធីការផ្សេងៗ



## ឧបសម្ព័ន្ធទី២

### នៃអនុក្រឹត្យលេខ ៤៧៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ២០១៥

### ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់ថ្នាក់អគ្គនាយក



# ឧបសម្ព័ន្ធទី៣

## នៃអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់អគ្គនាយករង



## ឧបសម្ព័ន្ធទី៤

**នៃអនុក្រឹត្យលេខ..៥២៤..អនក្រ..បក ចុះថ្ងៃទី..១០..... ខែ..មីនា..... ឆ្នាំ២០១៥**

**ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់**

**សញ្ញាសក្តិសម្រាប់ប្រធាននាយកដ្ឋាន**



# ឧបសម្ព័ន្ធទី៥

## នៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ០៣ ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់អនុប្រធាននាយកដ្ឋាន



## ឧបសម្ព័ន្ធទី៦

**នៃអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ២០១៥**

**ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់**

**សញ្ញាសក្តិសម្រាប់ប្រធានការិយាល័យ**



# ឧបសម្ព័ន្ធទី៧

**នៃអនុក្រឹត្យលេខ ៤២៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥**

**ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់**

**សញ្ញាសក្តិសម្រាប់អនុប្រធានការិយាល័យ**



## ឧបសម្ព័ន្ធទី៨

**នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥**

**ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់**

**សញ្ញាសក្តិសម្រាប់មន្ត្រី**



## ឧបសម្ព័ន្ធទី៩

**នៃអនុក្រឹត្យលេខ...២៤...អនក្រ.បក ចុះថ្ងៃទី...១០.... ខែ...មករា..... ឆ្នាំ២០១៥**

**ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់**

**សញ្ញាសក្តិសម្រាប់ត្អាក់ខារ**



## ឧបសម្ព័ន្ធទី១០

### នៃអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

### ស្ដីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### មួកកាស្កេត

| | |
|---|---|
|  | មួកកាស្កេត សម្រាប់ថ្នាក់អគ្គនាយក |
|  | មួកកាស្កេត សម្រាប់អគ្គនាយករង |
|  | មួកកាស្កេត សម្រាប់ប្រធាន អនុប្រធាននាយកដ្ឋាន |
|  | មួកកាស្កេត សម្រាប់ប្រធាន អនុប្រធានការិយាល័យ |
|  | មួកកាស្កេត មន្ត្រីផ្សេងទៀត |
|  | មួកកាស្កេត មន្ត្រីភ្នាក់ងារ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ធស/រកម/០១៩៦ /១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៤/០១៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញកិច្ចព្រមព្រៀងស្តីពីការបង្កើតនិងអនុវត្តបញ្ជរតែមួយអាស៊ាន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត "**គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**" ហៅកាត់ថា "**គ.ដ.ប.ជ**" ដើម្បីគ្រប់គ្រងការអភិវឌ្ឍ និងអនុវត្តគម្រោងបញ្ជរតែមួយជាតិ។

**គ.ដ.ប.ជ** ត្រូវមានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់បម្រើការងាររបស់ខ្លួន។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ដ.ប.ជ** ត្រូវកំណត់ដោយប្រធាន **គ.ដ.ប.ជ**។

## ជំពូកទី២

## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

**គ.ដ.ប.ជ** មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤. អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០. តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១១. តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១២. តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៣. តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១៤. តំណាងអាជ្ញាធរកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ១៥. តំណាងអាជ្ញាធរអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិក |

| | |
|---|---|
| ១៦. តំណាងអាជ្ញាធរកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ១៧. តំណាងសមាគមដឹកជញ្ជូនទំនិញផ្លូវគោកកម្ពុជា | សមាជិក |
| ១៨. តំណាងសមាគមអ្នកបញ្ជូនទំនិញកម្ពុជា | សមាជិក |
| ១៩. តំណាងសមាគមជើងសាគយ | សមាជិក |

**មាត្រា៣.-**

**គ.ជ.ប.ជ** ត្រូវបង្កើតក្រុមជំនាញ ដូចខាងក្រោម ៖

១. ក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយគម្រោងបញ្ជរតែមួយជាតិ ។

២. ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ ។

៣. ក្រុមការងារផ្សេងទៀត តាមការចាំបាច់។

## ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ជ.ប.ជ

**មាត្រា៤.-**

**គ.ជ.ប.ជ** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ៖

- បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ គ្រប់គ្រងការអភិវឌ្ឍ និង អនុវត្តបញ្ជរតែមួយជាតិ រាប់បញ្ចូលទាំងការតភ្ជាប់បញ្ជរតែមួយជាតិទៅបញ្ជរតែមួយអាស៊ានផង ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ស្របតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាលកម្ពុជា
- រៀបចំកសាងទស្សនទាន ចក្ខុវិស័យ ក្របខ័ណ្ឌច្បាប់ និងផែនការយុទ្ធសាស្ត្រអនុវត្តគម្រោង បញ្ជរតែមួយជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- គ្រប់គ្រងនិងត្រួតពិនិត្យការប្រើប្រាស់ថវិកាគម្រោង រាប់បញ្ចូលទាំងការពិនិត្យនិងអនុម័តលទ្ធកម្ម គម្រោង ដើម្បីធានាបាននូវការប្រើប្រាស់មូលនិធិគម្រោងត្រឹមត្រូវ
- ពិនិត្យនិងអនុម័តផែនការសកម្មភាព និងអនុសាសន៍ ដែលស្នើដោយក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់ និងគោលនយោបាយ និងក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ
- តាមដានសកម្មភាព និងវាយតម្លៃពីវឌ្ឍនភាពនៃការអភិវឌ្ឍ និងអនុវត្តគម្រោង
- ពិនិត្យ និងវាយតម្លៃលើសកម្មភាពចូលរួមអនុវត្តគម្រោងរបស់បណ្តាក្រសួង ស្ថាប័នជំនាញ និងវិស័យឯកជនពាក់ព័ន្ធ
- កំណត់តម្លៃសេវាប្រើប្រាស់បញ្ជរតែមួយជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា

- កែសម្រួល និង/ឬបំពេញបន្ថែមសមាសភាព**គ.ជ.ម.ជ** តាមការចាំបាច់
- ពិនិត្យ និងផ្តល់អនុសាសន៍លើការបង្កើតក្រុមការងារអភិវឌ្ឍនិងអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មតាមក្រសួង ស្ថាប័នជំនាញ និងសម្រាប់ប្រតិបត្តិការតភ្ជាប់ជាមួយបញ្ជរតែមួយជាតិ
- ស្វែងរកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ការអភិវឌ្ឍនិងអនុវត្តគម្រោងបញ្ជរតែមួយជាតិ
- ធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោងបញ្ជរតែមួយជាតិ ជូនរាជរដ្ឋាភិបាលកម្ពុជា
- អនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ជ.ម.ជ

**មាត្រា៥**.-

ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពការងារ និងនីតិវិធីប្រតិបត្តិរបស់ខ្លួនតាមការចាំបាច់ ។

**មាត្រា៦**.-

សមាជិកនៃ **គ.ជ.ម.ជ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធាន **គ.ជ.ម.ជ** ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន ឬ មានធុរៈ អនុប្រធានត្រូវដឹកនាំអង្គប្រជុំជំនួស។

ប្រធាន **គ.ជ.ម.ជ** អាចអញ្ជើញអ្នកជំនាញនិងតំណាងក្រសួង ស្ថាប័នដែលមិនមែនជាសមាជិកនៃ **គ.ជ.ម.ជ** ចូលរួមប្រជុំតាមការចាំបាច់។

## ជំពូកទី៥

## ប្រភពធនធាននិងមូលនិធិ

**មាត្រា៧**.-

ការចំណាយសម្រាប់ដំណើរការ**គ.ជ.ម.ជ** និងសម្រាប់អនុវត្តគម្រោងបញ្ជរតែមួយជាតិ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬថវិកាស្របច្បាប់ដែលបានមកពីប្រភពផ្សេងទៀត។

**គ.ជ.ម.ជ** មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួននិងសម្រាប់អនុវត្តគម្រោងបញ្ជរតែមួយជាតិ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

៤-ឯកឧត្តម **គាត ឈន់**÷ ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រី, ទទួលបន្ទុកការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ការងារអភិវឌ្ឍន៍វិស័យឯកជន, ការងារភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍជាមួយគូអង្គអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ, ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និងសម្រេចលើការងាររបស់ **"ច្រកចេញ-ចូលតែមួយ"** នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកលែងតែការងារដែលមានវេទយិតភាពខ្ពស់ ដែលតម្រូវឱ្យសុំការណែនាំឬការសម្រេចពីនាយករដ្ឋមន្ត្រី និងទទួលសិទ្ធិពីនាយក-រដ្ឋមន្ត្រីក្នុងការពិនិត្យនិងសម្រេចលើសំណើសុំកូន។

**ប្រការពីរ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី._**

នាយករដ្ឋមន្ត្រី, ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ . ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ដូចប្រការបី

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៦...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការជំនួយការ នៃគណៈកម្មាធិការរៀបចំកិច្ចប្រជុំបូកសរុប ដកពិសោធន៍សកម្មភាព ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្ត កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទីភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋានដើម្បី ត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា

- យោងសេចក្តីសម្រេចលេខ១៤សសរ ចុះថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំ កិច្ចប្រជុំបូកសរុប ដកពិសោធន៍សកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្ត កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា

**សម្រេច**

**ប្រការ១ .-**

បង្កើតអនុគណៈកម្មការជំនួយការ នៃគណៈកម្មាធិការរៀបចំ កិច្ចប្រជុំបូកសរុប ដកពិសោធន៍សកម្មភាព ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាដែលមានដូចខាងក្រោម៖

I. **អនុគណៈកម្មការឯកសារ**

| | | |
|---|---|---|
| ១-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-ឯកឧត្តម **លេខ ទី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៣-ឯកឧត្តម **ប៉ាវ ហមផាន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៤-ឯកឧត្តម **ខ៉ាន់ ចំរើន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៥-ឯកឧត្តម **ចៅ សេដ្ឋាណា** | អនុរដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | **អនុប្រធាន** |
| ៦-ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៧-ឯកឧត្តម **រស់ ករុណា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៨-លោកជំទាវ **ឡាយ អូនរី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៩-លោក **ឆាន់ ចន្ទសុភក្តិ** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **សមាជិក** |

**អនុគណៈកម្មការនេះមានភារកិច្ចៈ** រៀបចំរបាយការណ៍លទ្ធផលការងាររយៈពេលមួយឆ្នាំ២០១៤ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា និងទិសដៅបន្តឆ្នាំ២០១៥។ រៀបចំសុន្ទរកថាបើកនិងសុន្ទរកថាបិទ រៀបចំគំរូរបាយការណ៍ ព្រមទាំងធ្វើគំរោងចំណាយផ្សេងៗ សម្រាប់អនុគណៈកម្មការរបស់ខ្លួនជូនទៅអនុគណៈកម្មការផ្គត់ផ្គង់ ។

II. **អនុគណៈកម្មការពិធីការ និងរដ្ឋបាល**

| | | |
|---|---|---|
| ១-ឯកឧត្តម **លូ រ៉ាមីន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-ឯកឧត្តម **រាជ សុភទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក **ប៉ោ ភក្តិ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |

| | | |
|---|---|---|
| ៤-លោកជំទាវ **សុខ ស៊ីផន** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រីនិងជាប្រធានស្តីទីនាយកដ្ឋានពិធីការទីស្តីការគណៈរដ្ឋមន្ត្រី | **អនុប្រធាន** |
| ៥-លោកស្រី **លីម កិត្យា** | អនុប្រធាននាយកដ្ឋានពីធីការទីស្តីការគណៈរដ្ឋមន្ត្រី | **សមាជិក** |
| ៦-លោកឧត្តមសេនីយ៍ត្រី **ខេង សៅទិបុត្ត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៧-លោក **ហាខ្យ សុផល** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៨-លោក វរៈសេនីយ៍ត្រី **ហោ ស៊ីដែត** | ប្រធានការិយាល័យពិធីការ ក្រសួងមហាផ្ទៃ | **សមាជិក** |

**អនុគណៈកម្មការមានភារកិច្ចៈ** កំណត់សមាសភាពសមាជិកត្រូវអញ្ជើញអោយសមាមាត្រទៅនឹងសាលប្រជុំ។អញ្ជើញ និងទទួលបដិសណ្ឋារកិច្ចគណៈអធិបតី សមាជិក សមាជិកា និងភ្ញៀវចូលរួមប្រជុំ អ្នកកាសែត អ្នកយកព័ត៌មានវិទ្យុ ទូរទស្សន៍ កាន់កម្មវិធី រៀបចំសាលប្រជុំ ស្រង់វត្តមាន បែងចែកឯកសារ និងរៀបចំកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់កិច្ចប្រជុំទាំងមូល ព្រមទាំងធ្វើគំរោងចំណាយផ្សេងៗសម្រាប់អនុគណៈកម្មការរបស់ខ្លួនជូនទៅអនុគណៈកម្មការផ្គត់ផ្គង់ ។

### III. អនុគណៈកម្មការការពារ សន្តិសុខ និងសណ្តាប់ធ្នាប់

| | | |
|---|---|---|
| ១-ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ | **ប្រធាន** |
| ២-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | **អនុប្រធាន** |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក **ជួនសុវណ្ណ** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាស្នងការ នៃស្នងការដ្ឋានរាជធានីភ្នំពេញ | **អនុប្រធាន** |
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក **ទូច ណារ៉ុថ** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | **អនុប្រធាន** |
| ៥-លោកឧត្តមសេនីយ៍ទោ **រ័ត្ន ស្រ៊ាង** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេសនិងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | **សមាជិក** |
| ៦-លោកឧត្តមសេនីយ៍ទោ **សំ សាមឿន** | មេបញ្ជាការការពារសន្តិសុខ ទីស្តីការ គណៈរដ្ឋមន្ត្រី | **សមាជិក** |
| ៧-លោកឧត្តមសេនីទោ **មែល សំឡៀង** | ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ | **សមាជិក** |
| ៨-លោកឧត្តមសេនីយ៍ត្រី **ឡេង ហុង** | មេបញ្ជាការរងការពារសន្តិសុខ ទីស្តីការ គណៈរដ្ឋមន្ត្រី | **សមាជិក** |

**អនុគណៈកម្មការនេះ មានភារកិច្ចៈ** ការពារសន្តិសុខ សុវត្ថិភាព និងរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ ធ្វើគំរោងចំណាយផ្សេងៗសម្រាប់អនុគណៈកម្មការរបស់ខ្លួនជូនអនុគណៈកម្មការផ្គត់ផ្គង់ ។

### IV. អនុគណៈកម្មការផ្គត់ផ្គង់

| | | |
|---|---|---|
| ១-ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ ម៉ុនណារិន** | អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឯម សំណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន ភស្តុភា និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |

| | | |
|---|---|---|
| ៣-ឯកឧត្តម **សេង យូអ៊ាន់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារនិង ហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្នែកស៊ីវិល ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក **ច័ន្ទ សុវណ្ណា** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៥-លោកឧត្តមសេនីយ៍ត្រី **យស់ វីរៈ** | អនុប្រធានលេខាធិការ នៃលេខាធិការដ្ឋាន អគ្គនាយកដ្ឋានភស្តុភានិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៥-លោកឧត្តមសេនីយ៍ត្រី **ខា សុគន្ធា** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្នែកសន្តិសុខ ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៦-លោក **ហួត ដាវិត** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | **សមាជិក** |

**អនុគណៈកម្មការនេះមានភារកិច្ចៈ** បូកសរុបរាល់គម្រោងចំណាយនានា ដែលបម្រើដល់ការរៀបចំអង្គប្រជុំនេះ ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេច។

**ប្រការ២ .-**

អនុគណៈកម្មការនីមួយៗ មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទ ដើម្បីជួយការងារតាមការចាំបាច់។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៥

**ត.ប. នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

<u>កន្លែងទទួលៈ</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧ សសរ

# សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល,

### <u>សម្រេច</u>

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ទៅចូលរួមសន្និសីទពិភពលោកលើកទី ៣ របស់អង្គការសហប្រជាជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅទីក្រុងសេនដាយ ប្រទេសជប៉ុន ចាប់ពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៥ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីអញ្ជើញ វិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..០៧..សរ...**

# សារាចរ
## ស្តីពី
## ការបើកផ្តល់បៀវត្សសម្រាប់ខែមេសា ឆ្នាំ២០១៥ និងប្រាក់ឧបត្ថម្ភ ក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិ ឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩

នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០១៥នេះ រាជរដ្ឋាភិបាលបានធ្វើការកែសម្រួលប្រព័ន្ធបៀវត្សមន្ត្រីរាជការ ដោយបានធ្វើការកែសម្រួលនិងដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ គ្រូបង្រៀនជាប់កិច្ចសន្យានៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងការបង្កើនប្រាក់តំបន់ជូនមន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដែលបម្រើការងារនៅតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល ព្រមទាំងបានសម្រេចផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩ ចំនួន ៤០០០០ (បួនម៉ឺន) រៀលក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិលនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ មន្ត្រីនគរបាលជាតិកម្ពុជា យោធិននៃកងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ដែលកំពុងបម្រើការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ និងជនពិការ ដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយោធិននៃកងយោធពលខេមរភូមិន្ទ អតីតមន្ត្រីនគរបាលជាតិកម្ពុជា។

ដើម្បីធានាឲ្យការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រព្រឹត្តទៅដោយរលូននិងបានទាន់ពេលវេលាមុនថ្ងៃចូលឆ្នាំថ្មីប្រពៃណីជាតិ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

១- ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវរៀបចំកែសម្រួលតារាងសន្ទស្សន៍បៀវត្សថ្មីជូនមន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទ ឱ្យបានរួចរាល់ក្នុងខែមីនា ឆ្នាំ២០១៥ អនុលោមបញ្ញត្តិនៃអនុក្រឹត្យជាធរមាន

២- ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលតាមតារាងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិលជាស្វ័យប្រវត្តិឱ្យបានរួចរាល់ក្នុងខែមីនាឆ្នាំ២០១៥ ហើយបញ្ជូនទៅក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត និងមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ដើម្បីប្រើប្រាស់សម្រាប់ការបើកផ្តល់បៀវត្សក្នុងខែមេសា ឆ្នាំ២០១៥ តែម្តង

៣- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវរៀបចំគម្រោងស្នើសុំឥណទានសម្រាប់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មី មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវមានការសហការគ្នាដើម្បីចាត់ចែងនិងរៀបចំបែបបទនិងនីតិវិធីនៃការបើកផ្តល់ឱ្យបានរួចរាល់ត្រឹមដំណាច់ខែមីនា ឆ្នាំ២០១៥

៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី ត្រូវសហការនិងចាត់ចែងរៀបចំការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីឱ្យដល់សាមីជនម្នាក់ៗ គ្រប់ចំនួននិងយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០៦៩ ...... ក.ប/ប្រ.ក

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ សន/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**<u>សម្រេច</u>**

**ប្រការ ១**.- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទទួលបន្ទុកការងារតាក់តែងគោលនយោបាយអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនិងគ្រប់គ្រងលើការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងតាមច្បាប់ស្តីពីការងារ ប្រមូលចងក្រង និងគ្រប់គ្រងព័ត៌មានទីផ្សារការងារក្នុង និងក្រៅប្រទេស ធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអភិវឌ្ឍស្តង់ដានិងកម្មវិធីសិក្សា។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ ២**.- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដឹកនាំដោយអគ្គនាយកមួយរូប និង មានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**ប្រការ ៣**.- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមាននាយកដ្ឋានចំនួន ៦ និង លេខាធិការដ្ឋាន ១ រួមមាន៖

១-នាយកដ្ឋានព័ត៌មានទីផ្សារការងារ

២-នាយកដ្ឋានបណ្តុះបណ្តាល

៣-នាយកដ្ឋានស្តង់ដានិងកម្មវិធីសិក្សា

៤-នាយកដ្ឋានធានាគុណភាព

៥-នាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ

៦-នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា

៧-លេខាធិការដ្ឋាន

**ប្រការ ៤**.- នាយកដ្ឋានចំណុះឲ្យអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅដាច់ដោយឡែក។

**ប្រការ ៥**.- លេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានរចនាសម្ព័ន្ធស្មើនឹងការិយាល័យនៅថ្នាក់កណ្តាល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។ លេខាធិការដ្ឋានមានភារកិច្ចដូចតទៅ៖

- សម្របសម្រួលរាល់ឯកសារលិខិតចេញ-ចូល របស់អគ្គនាយកដ្ឋាន
- សម្របសម្រួលរាល់កិច្ចការរបស់អគ្គនាយកដ្ឋាន ជាមួយទីស្តីការក្រសួង នាយកដ្ឋាននានាក្រោមឱវាទក្រសួង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ និង ដៃគូអភិវឌ្ឍន៍នានា
- គ្រប់គ្រង និងចរាចររាល់ឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- រៀបចំទុកដាក់ ថែរក្សា និងគ្រប់គ្រងរាល់ឯកសារ លិខិតរបស់អគ្គនាយកដ្ឋាន
- ថែរក្សា គ្រប់គ្រងសម្ភារ បរិក្ខារ ចលនទ្រព្យ និងអចលនទ្រព្យនានារបស់អគ្គនាយកដ្ឋាន
- ណែនាំរបៀបរបបការងាររដ្ឋបាលរបស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋាន
- រៀបចំអង្គប្រជុំ និងធ្វើរបាយការណ៍ ឬកំណត់ហេតុអង្គប្រជុំរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន

**ប្រការ ៦**.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។ ៕

**ប្រការ ៧.**- នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

អ៊ិត សំហេង

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ:** ០៦៦/១៥ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥



**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០៦៧/១៥..........**ក.ប**/ប្រ.ក

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានព័ត៌មានទីផ្សារការងារ**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ សន/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**<u>សម្រេច</u>**

**ប្រការ ១**.- នាយកដ្ឋានព័ត៌មានទីផ្សារការងារ ជាអង្គភាពមួយក្រោមឱវាទអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានភារកិច្ចដូចខាងក្រោម៖

- ចងក្រង និងផ្សព្វផ្សាយមុខរបរអាទិភាពនៅក្នុងប្រទេសកម្ពុជា
- ប្រមូលទិន្នន័យអំពីតម្រូវការនៃទីផ្សារការងារ ដើម្បីរៀបចំឲ្យមានតុល្យភាពរវាងការបណ្តុះបណ្តាល ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មឲ្យស្របតាមទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស
- កសាងស្ថិតិការងារដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទក្រសួង៕



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- រៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានទិន្នន័យស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- រៀបចំយុទ្ធសាស្ត្រទីផ្សារទាក់ទាញសិស្ស និស្សិតឲ្យមកសិក្សាក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកាន់តែទូលំទូលាយ
- សម្របសម្រួលភាពជាដៃគូរវាងឧស្សាហកម្ម និងអ្នកផ្តល់ការបណ្តុះបណ្តាល ជាពិសេសក្រុមការងារទំនាក់ទំនងឧស្សាហកម្មនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**ប្រការ ២**.- នាយកដ្ឋានព័ត៌មានទីផ្សារការងារ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

នាយកដ្ឋានព័ត៌មានទីផ្សារការងារ មានការិយាល័យចំណុះចំនួន ៦ គឺ៖

១-ការិយាល័យរដ្ឋបាល

២-ការិយាល័យស្ថិតិការងារ

៣-ការិយាល័យព័ត៌មានទីផ្សារការងារ

៤-ការិយាល័យផ្សព្វផ្សាយ និងទីផ្សារ

៥-ការិយាល័យគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា

៦-ការិយាល័យទំនាក់ទំនងឧស្សាហកម្ម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

ចំពោះភារកិច្ចរបស់ការិយាល័យនីមួយៗមានដូចខាងក្រោម៖

**១-ការិយាល័យរដ្ឋបាល** មានភារកិច្ច៖

- សហការជាមួយការិយាល័យដទៃទៀតក្នុងនាមនាយកដ្ឋានដើម្បីធ្វើការងារបូកសរុប និងលើកទិសដៅការងាររួម
- ការងាររបៀប (លិខិតចេញ លិខិតចូល)
- គ្រប់គ្រងបញ្ជី និងប្រវត្តិរូបមន្ត្រីរាជការ
- រៀបចំផែនការសកម្មភាពការងារ និងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំសំណុំឯកសារប្រាក់បៀវត្សរបស់មន្ត្រីរាជការ
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងធ្វើថ្មីនៅពេលមានការផ្លាស់ប្តូរ
- គ្រប់គ្រងអចលនទ្រព្យ និងចលនទ្រព្យរបស់នាយកដ្ឋាន
- ការងារសន្តិសុខ សណ្តាប់ធ្នាប់ យាមកាម និងអនាម័យ
- រៀបចំលិខិត ដើម្បីបញ្ចូល ឬបញ្ជូនបៀវត្សសម្រាប់មន្ត្រីផ្ទេរចេញ និងផ្ទេរចូល ប្រពន្ធផ្ទេរតាមប្តី ឬទើបរៀបការ និងកូនទើបកើត និងមន្ត្រីចូលនិវត្តន៍
- រៀបចំលិខិតតម្លើងកាំប្រាក់ និងបៀវត្ស និងការទទួលស្គាល់ស្នាដៃការងារ

- រៀបចំតាក់តែងលិខិតបទដ្ឋាន លិខិតរដ្ឋបាលនានា ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញ និងវិសាមញ្ញរបស់នាយកដ្ឋាន
- រៀបចំពិធីការ និងដំណើរការរាល់កិច្ចប្រជុំ និងជំនួបផ្សេងៗរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន ដោយធ្វើការសហការជាមួយការិយាល័យពាក់ព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

២-ការិយាល័យស្ថិតិការងារ មានភារកិច្ចៈ

- រៀបចំប្រព័ន្ធស្ថិតិការងារនៅតាមនាយកដ្ឋានពាក់ព័ន្ធ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ដើម្បីចងក្រងទិន្នន័យស្ថិតិការងារដែលដកស្រង់ចេញពីកំណត់ត្រារដ្ឋបាលការងារ
- ប្រមូល និងចងក្រងទិន្នន័យស្ថិតិការងារទាក់ទងនឹងចំនួនកម្មករ-និយោជិតរកការងារធ្វើ ចំនួនកម្មករ-និយោជិតបរទេស អធិការកិច្ចការងារ ប្រាក់ឈ្នួល ចំនួនម៉ោងធ្វើការ ចំនួនវិវាទការងារ ចំនួនអង្គការវិជ្ជាជីវៈ ពេទ្យការងារ គ្រោះថ្នាក់ការងារសន្តិសុខសង្គមចំនួន និងប្រភេទនៃរោងចក្រ សហគ្រាស គ្រឹះស្ថាន
- ធ្វើការបណ្តុះបណ្តាលបច្ចេកទេសដល់មន្ត្រីដែលទទួលបន្ទុកស្ថិតិការងាររបស់នាយកដ្ឋានពាក់ព័ន្ធ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងអង្គភាពផ្សេងទៀត
- ណែនាំបច្ចេកទេស និងតាមដានការអនុវត្តន៍របស់មន្ត្រីទទួលបន្ទុកស្ថិតិការងារនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធផ្សេងទៀត
- ធ្វើរបាយការណ៍ស្តីពីស្ថិតិការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បោះពុម្ព និងផ្សព្វផ្សាយរបាយការណ៍ស្តីពីស្ថិតិការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ធ្វើបញ្ជីរាយឈ្មោះមុខរបរ និងដាក់លេខកូដសម្គាល់
- ស្រាវជ្រាវមុខរបរសំខាន់ៗនៅតាមភូមិ ឃុំ ដើម្បីជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលក្រៅប្រព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

៣-ការិយាល័យព័ត៌មានទីផ្សារការងារ មានភារកិច្ចៈ

- រៀបចំឲ្យមានកញ្ចប់ព័ត៌មានរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនីមួយៗ
- រៀបចំឲ្យមានស្ថិតិសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន និងកម្មករ-និយោជិត ដោយចាត់ថ្នាក់តាមសកម្មភាពសេដ្ឋកិច្ច និងមុខរបរ

- រៀបចំផែនការអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានទីផ្សារការងារដោយសហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ធ្វើទំនាក់ទំនងគ្រប់ផ្នែក អង្គភាព ស្ថាប័ន ដែលពាក់ព័ន្ធដើម្បីក្តាប់ឲ្យបាននូវព័ត៌មានទីផ្សារការងារ
- និពន្ធ ផលិត ចងក្រងឯកសារ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារដោយសហការជាមួយគ្រប់ស្ថាប័នដែលពាក់ព័ន្ធ
- រៀបចំកញ្ចប់ព័ត៌មានរបស់និយោជក និងតម្រូវការកម្លាំងពលកម្ម
- ប្រមូល ចងក្រង និងវិភាគទិន្នន័យស្តីពីការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម និងការព្យាករណ៍ក្នុងពេលអនាគតតាមប្រភេទនៃមុខរបរ ជំនាញ និងវិស័យ
- ប្រមូល ចងក្រង និងវិភាគទិន្នន័យស្តីពីប្រាក់ឈ្នួល និងអត្រាគ្មានការងារធ្វើ ក្នុងពេលបច្ចុប្បន្ន និងការព្យាករណ៍ក្នុងពេលអនាគត
- ប្រមូល ចងក្រង និងវិភាគទិន្នន័យស្តីពីតម្រូវការកម្លាំងពលកម្មរបស់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងទទួលបានការអនុម័តពីរាជរដ្ឋាភិបាល
- ធ្វើទំនាក់ទំនងជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដើម្បីស្វែងរកទិន្នន័យ និងសូចនាករនានាដែលបានមកពីការធ្វើជំរឿនប្រជាជនការអង្កេតកម្លាំងពលកម្ម ការអង្កេតសហគ្រាស គ្រឹះស្ថាន ការអង្កេតគ្រួសារ ដូចជាៈ ចំនួនប្រជាជនសរុប ចំនួនប្រជាជនស្ថិតក្នុងកម្លាំងពលកម្ម អត្រាចូលរួមក្នុងកម្លាំងពលកម្ម អត្រាមានការងារធ្វើ អត្រាមានការងារធ្វើមិនពេញលេញ អត្រាគ្មានការងារធ្វើ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៤- ការិយាល័យផ្សព្វផ្សាយ និងទីផ្សារ មានភារកិច្ចៈ**

- រៀបចំយុទ្ធសាស្ត្រទីផ្សារទាក់ទាញសិក្ខាកាម សិស្ស និស្សិត ដើម្បីឲ្យចូលមកសិក្សាក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័ននានា ដើម្បីផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យកាន់តែទូលំទូលាយ
- រៀបចំផែនការ និងយុទ្ធសាស្ត្រសម្រាប់ធ្វើការផ្សព្វផ្សាយអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ចងក្រងឯកសាររូបភាព និងសកម្មភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- លើកផែនការបោះពុម្ព និងផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៗ

- រៀបចំជាស្ពត់ផ្សព្វផ្សាយការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន។ល។
- ផ្សព្វផ្សាយព័ត៌មានទៅដល់ជនបទ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៥-ការិយាល័យគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា** មានភារកិច្ច៖

- រៀបចំលិខិតបទដ្ឋានគតិយុត្តនានាក្នុងការប្រមូលទិន្នន័យ និងអភិវឌ្ឍទិន្នន័យ
- រៀបចំយន្តការប្រមូល និងបញ្ចូលស្ថិតិទៅក្នុងប្រព័ន្ធ TVET-MIS
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ TVET-MIS
- សហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជននៅតាមរាជធានី-ខេត្ត ក្នុងការប្រមូលទិន្នន័យ
- រៀបចំចងក្រង វិភាគ គ្រប់គ្រងទិន្នន័យ និងសរសេររបាយការណ៍ស្តីពីវឌ្ឍនភាពនៃវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- តាមដាន ថែទាំ និងអភិវឌ្ឍប្រព័ន្ធផ្ទុកទិន្នន័យ
- រៀបចំបោះពុម្ពជាសៀវភៅ(ពីរភាសា)សម្រាប់ជូនភ្ញៀវស្តីពីគ្រឹះស្ថានសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមកម្រិតនីមួយៗព្រមទាំងជំនាញ និងរយៈពេលបណ្តុះបណ្តាល
- ធ្វើទំនាក់ទំនងជាមួយការិយាល័យជំនាញផ្សេងៗ ដែលពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យ
- ដំឡើង កែលំអ ថែទាំ ជួសជុលប្រព័ន្ធគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា TVET-MIS
- អភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកលើការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា TVET-MIS
- បោះពុម្ព និងផ្សព្វផ្សាយនូវទិន្នន័យ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៦-ការិយាល័យទំនាក់ទំនងឧស្សាហកម្ម** មានភារកិច្ច៖

- សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំអនុសាសន៍ដើម្បីបង្កើនភាពជាដៃគូរវាងរដ្ឋ និងឯកជន
- កំណត់នូវបញ្ហាដែលពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលរបស់ឧស្សាហកម្ម ឬផ្នែកផ្សេងៗស្រប ទៅតាមតម្រូវការទីផ្សារការងារ

- ទំនាក់ទំនងជាមួយអ្នកផ្តល់ការបណ្តុះបណ្តាល ដើម្បីផ្តល់ជាយោបល់លើការអភិវឌ្ឍកម្មវិធីសិក្សា និងស្តង់ដាបណ្តុះបណ្តាលដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្មក្នុង និងក្រៅប្រទេស
- សម្របសម្រួលរវាងអ្នកផ្តល់ការបណ្តុះបណ្តាល និងផ្នែកឧស្សាហកម្មលើកម្មវិធីកម្មសិក្សារបស់សិក្ខាកាម សិស្ស និស្សិត និងការស្វែងរកការងារធ្វើរបស់អ្នកដែលទើបបានបញ្ចប់ការសិក្សា
- ផ្តល់សេវាផ្សព្វផ្សាយការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទៅតាមសហគ្រាសឧស្សាហកម្ម និងស្ថាប័នផ្សេងៗ
- សម្របសម្រួលការងារជាមួយក្រុមការងារទំនាក់ទំនងឧស្សាហកម្មនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអង្គភាពពាក់ព័ន្ធ
- រៀបចំ និងសម្របសម្រួលការចុះកម្មសិក្សារបស់សិក្ខាកាម សិស្ស និស្សិតជាមួយរោងចក្រឧស្សាហកម្មដោយសហការជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការលើការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍមុខជំនាញក្នុងទីផ្សារឧស្សាហកម្មក្នុង និងក្រៅប្រទេស
- ពង្រឹង និងពង្រីកភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣**.- អង្គការលេខរបស់នាយកដ្ឋានព័ត៌មានទីផ្សារការងារជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤**.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥**.- នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ឝ៊ិត សំហេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥

**ឧបសម្ព័ន្ធប្រកាសលេខ:** ០៦២/១៥ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០១៥



**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........០៣៧/១៥.............**ក.ប**/ប្រ.ក

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបណ្តុះបណ្តាល**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ សន/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**<u>សម្រេច</u>**

**ប្រការ ១**.- នាយកដ្ឋានបណ្តុះបណ្តាល ជាអង្គភាពមួយក្រោមឱវាទអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំឯកសារ និងទម្រង់បែបបទដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃការងារបណ្តុះបណ្តាល



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ:(០២៣)៨៨ ២៧ ៦៩

- ចូលរួមក្នុងបណ្តាញបណ្តុះបណ្តាលជាមួយអ្នកផ្តល់ការបណ្តុះបណ្តាលក្នុងប្រទេសរដ្ឋជាសមាជិកអាស៊ាន និងអន្តរជាតិ
- ធ្វើទំនាក់ទំនង សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុននានា សំដៅជម្រុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង
- រៀបចំផែនការនិងកម្មវិធីបណ្តុះបណ្តាល ពិសេសដល់ក្រុមគោលដៅ
- រៀបចំកម្មវិធីសិក្សាពីចម្ងាយ ការសិក្សាបន្ត ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ការសិក្សាមុខវិជ្ជាថ្មីៗសម្រាប់បណ្តុះបណ្តាល
- សហការជាមួយគ្រឹះស្ថានសិក្សារៀបចំផែនការបណ្តុះបណ្តាលតាមកម្រិតនីមួយៗ
- អនុវត្តគោលនយោបាយស្តីពីសមភាពរវាងបុរស និងស្ត្រីក្នុងកម្មវិធីបណ្តុះបណ្តាល
- បំពាក់មូលដ្ឋានឧបករណ៍ និងសម្ភារៈដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- សម្របសម្រួលជាមួយអ្នកផ្តល់ការបណ្តុះបណ្តាល រៀបចំចងក្រងជាក្រុមសិក្ខាកាមសិស្ស និស្សិតដែលចង់ប្រកបមុខរបរដោយខ្លួនឯង ដើម្បីផ្តល់ប្រាក់កម្ចីដល់ក្រុមទាំងនោះ
- កំណត់កាលបរិច្ឆេទ និងអនុវត្តការប្រឡងជ្រើសរើស និងប្រឡងបញ្ចប់របស់សិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាប្រចាំឆ្នាំនីមួយៗ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន ។

**ប្រការ ២**.- នាយកដ្ឋានបណ្តុះបណ្តាល ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

នាយកដ្ឋានបណ្តុះបណ្តាល មានការិយាល័យចំណុះចំនួន ៧ គឺៈ

១-ការិយាល័យរដ្ឋបាល

២-ការិយាល័យបណ្តុះបណ្តាលក្នុងប្រព័ន្ធ

៣-ការិយាល័យបណ្តុះបណ្តាលក្រៅប្រព័ន្ធ

៤-ការិយាល័យបណ្តុះបណ្តាលពិសេស និងយេនឌ័រ

៥-ការិយាល័យហ្វឹកហ្វឺនកូនជាង

៦-ការិយាល័យមូលនិធិបង្កើតមុខរបរដោយខ្លួនឯង

៧-ការិយាល័យប្រឡង

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

ចំពោះភារកិច្ចរបស់ការិយាល័យនីមួយៗមានដូចខាងក្រោមៈ

**១-ការិយាល័យរដ្ឋបាល** មានភារកិច្ចៈ

- សហការជាមួយការិយាល័យដទៃទៀតក្នុងនាមនាយកដ្ឋានដើម្បីធ្វើការងារបូកសរុប និងលើកទិសដៅការងាររួម
- ការងាររបៀប (លិខិតចេញ លិខិតចូល)

- គ្រប់គ្រងបញ្ជី និងប្រវត្តិរូបមន្ត្រីរាជការរៀបចំផែនការសកម្មភាពការងារ និងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំសំណុំឯកសារប្រាក់បៀវត្សរបស់មន្ត្រីរាជការ
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងធ្វើថ្មីនៅពេលមានការផ្លាស់ប្តូរ
- គ្រប់គ្រងអចលនទ្រព្យ និងចលនទ្រព្យរបស់នាយកដ្ឋាន
- ការងារសន្តិសុខ សណ្តាប់ធ្នាប់ យាមកាម និងអនាម័យ
- រៀបចំលិខិត ដើម្បីបញ្ចូល ឬបញ្ជូនបៀវត្សសម្រាប់មន្ត្រីផ្ទេរចេញ និងផ្ទេរចូល ប្រពន្ធផ្ទេរតាមប្តី ឬទើបរៀបការ និងកូនទើបកើត និងមន្ត្រីចូលនិវត្តន៍
- រៀបចំលិខិតដំឡើងកាំប្រាក់ និងបៀវត្ស និងការទទួលស្គាល់ស្នាដៃការងារ
- រៀបចំតាក់តែងលិខិតបទដ្ឋាន លិខិតរដ្ឋបាលនានា ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញ និងវិសាមញ្ញរបស់នាយកដ្ឋាន
- រៀបចំពិធីការ និងដំណើរការរាល់កិច្ចប្រជុំ និងជំនួបផ្សេងៗរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន ដោយធ្វើការសហការជាមួយការិយាល័យពាក់ព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**២-ការិយាល័យបណ្តុះបណ្តាលក្នុងប្រព័ន្ធ** មានភារកិច្ចៈ

- កំណត់ចំនួន និងជំនាញធ្វើការបណ្តុះបណ្តាលប្រចាំឆ្នាំស្របតាមព័ត៌មានទីផ្សារ និងលទ្ធភាពនៃមូលដ្ឋានសម្ភារ និងធនធានមនុស្ស
- កំណត់ពីប្រភេទដែលត្រូវបណ្តុះបណ្តាលក្នុងប្រព័ន្ធ
- រៀបចំឯកសារ និងទម្រង់បែបបទដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ
- រៀបចំផែនការសកម្មភាពការងារ និងគម្រោងថវិកាចំណាយប្រចាំឆ្នាំ
- គ្រប់គ្រងស្ថិតិសិស្ស និស្សិត បានបញ្ចប់ការបណ្តុះបណ្តាល និងមានការងារធ្វើ
- រៀបចំផែនការបំពាក់មូលដ្ឋានឧបករណ៍សម្ភារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដល់គ្រឹះស្ថានសិក្សា
- ត្រួតពិនិត្យការអនុវត្តផែនការបណ្តុះបណ្តាលក្នុងប្រព័ន្ធ តាមគ្រឹះស្ថានសិក្សានីមួយៗ
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃដំណើរការបណ្តុះបណ្តាលក្នុងប្រព័ន្ធ
- រៀបចំកម្មសិក្សារបស់សិស្ស និស្សិត នៅតាមគ្រឹះស្ថានសាធារណៈ ឯកជន និងរោងចក្រសហគ្រាសនានា
- សហការជាមួយផ្នែកឧស្សាហកម្មក្នុងការបណ្តុះបណ្តាល ដើម្បីធានាបាននូវគុណភាព និងភាពជឿជាក់
- ចូលរួមក្នុងបណ្តាញបណ្តុះបណ្តាល ជាមួយរដ្ឋជាសមាជិកអាស៊ាន និងអ្នកបណ្តុះបណ្តាលក្នុងស្រុក
- ចងក្រងជាសមាគម ឬបណ្តាញអ្នកដែលបានបញ្ចប់ការសិក្សា

- សហការជាមួយគ្រឹះស្ថានសិក្សារាជធានី ខេត្ត-និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលក្នុងប្រព័ន្ធ
- សហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រឹះស្ថានសិក្សារាជធានី-ខេត្ត ដើម្បីរៀបចំបញ្ជីឈ្មោះសមាគមអ្នកផ្តល់ការបណ្តុះបណ្តាល និងអភិវឌ្ឍផែនការបណ្តុះបណ្តាលក្នុងប្រព័ន្ធ
- ផ្តល់ព័ត៌មាន និងយោបល់ដល់នាយកដ្ឋានអំពីតម្រូវការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងប្រព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៣-ការិយាល័យបណ្តុះបណ្តាលក្រៅប្រព័ន្ធ** មានភារកិច្ចៈ

- រៀបចំឯកសារ និងទម្រង់បែបបទដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលក្រៅប្រព័ន្ធដូចជា កម្មវិធីទ្រទ្រង់គ្រឹះស្ថានសិក្សារយៈពេលខ្លី កម្មវិធីបណ្តុះបណ្តាលបច្ចេកទេសក្រោយពេលប្រមូលផល និងកែច្នៃម្ហូបអាហារ កម្មវិធីស្ពានចម្លងបន្តជំនាញ និងការបណ្តុះបណ្តាលជាមួយឧស្សាហកម្ម
- រៀបចំផែនការសកម្មភាពការងារ និងគម្រោងថវិកាចំណាយប្រចាំឆ្នាំក្នុងការបណ្តុះបណ្តាលក្រៅប្រព័ន្ធ
- រៀបចំផែនការបំពាក់សម្ភារឧបទ្ទេសសម្រាប់វគ្គខ្លី
- គ្រប់គ្រងស្ថិតិសិក្ខាកាម ដែលបានបញ្ចប់ការបណ្តុះបណ្តាលក្រៅប្រព័ន្ធ និងអ្នកមានការងារធ្វើ
- ត្រួតពិនិត្យការអនុវត្តផែនការបណ្តុះបណ្តាលតាមគ្រឹះស្ថានសិក្សានីមួយៗ ក្នុងសកម្មភាពការបណ្តុះបណ្តាលក្រៅប្រព័ន្ធ
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃដំណើរការបណ្តុះបណ្តាលក្រៅប្រព័ន្ធ
- សហការជាមួយគ្រឹះស្ថានសិក្សារាជធានី-ខេត្ត និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលក្រៅប្រព័ន្ធ
- សហការជាមួយការិយាល័យធ្វើតេស្តសមត្ថភាពនៃនាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សាដើម្បីវាយតម្លៃទទួលស្គាល់ការបណ្តុះបណ្តាល ការទទួលស្គាល់គុណវុឌ្ឍិតាមកម្រិត នៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- សហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងគ្រឹះស្ថានសិក្សារាជធានី-ខេត្ត ដើម្បីរៀបចំបញ្ជីឈ្មោះសមាគមអ្នកផ្តល់ការបណ្តុះបណ្តាល និងអភិវឌ្ឍផែនការបណ្តុះបណ្តាលក្រៅប្រព័ន្ធ
- ផ្តល់ព័ត៌មាន និងយោបល់ដល់នាយកដ្ឋានអំពីតម្រូវការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រៅប្រព័ន្ធ
- រៀបចំសៀវភៅបញ្ជីឈ្មោះសិស្សបញ្ចប់ការសិក្សាថ្មីៗ ជំនាញ និងលេខទូរស័ព្ទ

- ធ្វើការសម្របសម្រួលក្នុងការរៀបចំ និងអភិវឌ្ឍផែនការអាជីវកម្មដល់សិក្ខាកាម សិស្ស និស្សិត ជនងាយរងគ្រោះ និងជនជាតិភាគតិចដែលទើបបញ្ចប់ការសិក្សា
- អភិវឌ្ឍអាជីវកម្មខ្នាតតូច និងសហគ្រិនភាព
- ត្រួតពិនិត្យ និងតាមដានលើការប្រកបអាជីវកម្មរបស់ក្រុមគោលដៅ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៤- ការិយាល័យបណ្តុះបណ្តាលពិសេស និងយេនឌ័រ** មានភារកិច្ចៈ

**ក -ការអប់រំបណ្តុះបណ្តាលពិសេស**

- រៀបចំគោលនយោបាយ និងគ្រប់គ្រងជំនាញមុខរបរដែលបានបណ្តុះបណ្តាលតាមប្រពៃណី ក្នុងគ្រួសារតាមសហគមន៍នានា
- រៀបចំផែនការ និងកម្មវិធីបង្កើនសមត្ថភាពជំនាញដល់ក្រុមគោលដៅ
- ផ្តល់ឱកាសដល់ជនងាយរងគ្រោះជាងគេ និងក្រុមគោលដៅទទួលបានជំនាញជាក់លាក់ ហើយអាចមានលទ្ធភាពទទួលបានការងារធ្វើ
- ធ្វើទំនាក់ទំនងជាមួយអង្គការជាតិ និងអន្តរជាតិដើម្បីស្វែងរកប្រភពទុនសម្រាប់កម្មវិធី បណ្តុះបណ្តាលពិសេសដល់ក្រុមជនមុខសញ្ញា
- រៀបចំកម្មវិធីសិក្សាស្រាវជ្រាវកម្មវិធីសិក្សាពីចំងាយ ការសិក្សាបន្តតាមប្រព័ន្ធអេឡិចត្រូនិច ការសិក្សាមុខវិជ្ជាថ្មីៗ សម្រាប់បណ្តុះបណ្តាលពិសេសដល់ក្រុមមុខសញ្ញា
- រៀបចំកម្មវិធី និងអប់រំបណ្តុះបណ្តាលពិសេសសម្រាប់ធានាសមធម៌ក្នុងការទទួលបានការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់ក្រុមមុខសញ្ញាពិសេស ដូចជាជនពិការ ជនងាយ ជួបការលំបាកជាងគេ ជាពិសេសនារីភេទ និងជនជាតិភាគតិចនៅតាមតំបន់ដាច់ស្រយាល និង តាមសហគមន៍
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ និងកម្មវិធីបណ្តុះបណ្តាលពិសេស
- សិក្សាស្រាវជ្រាវ និងរកឲ្យឃើញនូវមុខរបរសំខាន់ៗជាប្រពៃណីក្នុងគ្រួសារតាមរាជធានី-ខេត្ត និងសហគមន៍
- សហការជាមួយរាជធានី-ខេត្ត និងសហគមន៍រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈតាម ប្រពៃណី
- រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលមន្ត្រីជំនាញលើការងារអប់រំសុខភាព និងអនាម័យនៅ តាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- សិក្សាពីតម្រូវការបណ្តុះបណ្តាលនៅមូលដ្ឋានផ្ទាល់របស់ក្រុមមុខសញ្ញា
- អប់រំ និងអភិវឌ្ឍការបណ្តុះបណ្តាលនៅមូលដ្ឋានរបស់ក្រុមមុខសញ្ញា

**ខ -ការងារយេនឌ័រ**

- អនុវត្តគោលនយោបាយស្តីពីសមភាពរវាងបុរស និងស្ត្រី

- បង្កើនទំនាក់ទំនងរវាងស្ត្រីពីស្ថាប័នមួយទៅស្ថាប័នមួយ ដើម្បីធ្វើឱ្យមានការគាំទ្រដល់ក្រុមដែលគ្មានឱកាសចូលរួមសហការផ្តល់យោបល់ និងធ្វើឱ្យប្រសើរឡើងនូវសមភាពរវាងបុរស និងស្ត្រី ក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- រៀបចំគម្រោង និងដំណើរការបណ្តុះបណ្តាលមន្ត្រីរាជការស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងស្ថាប័ន
- ធ្វើការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើស្ថិតិ ទិន្នន័យនៃសកម្មភាពការងារសមភាពរវាងបុរស និងស្ត្រីនៅតាមអង្គភាព ទាំងសាធារណៈ ឯកជនដែលពាក់ព័ន្ធ
- រៀបចំផែនការសកម្មភាពការងារ និងគម្រោងថវិកាចំណាយប្រចាំឆ្នាំ
- សហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងគ្រឹះស្ថានសិក្សាផ្សេងៗ នៅក្នុងការអនុវត្តយុទ្ធសាស្ត្រទីផ្សារតាមរយៈការសិក្សាអស់មួយជីវិត និងដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រឹះស្ថានសិក្សារបស់ខ្លួន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៥-ការិយាល័យហ្វឹកហ្វឺនកូនជាង** មានភារកិច្ចៈ

- រៀបចំចងក្រងបទប្បញ្ញត្តិគតិយុត្តផ្សេងៗ ដែលទាក់ទងការហ្វឹកហ្វឺនកូនជាង
- ត្រួតពិនិត្យការហ្វឹកហ្វឺនកូនជាង កំណត់កម្មវិធីតាមមុខរបរនីមួយៗ ប្រឡងបញ្ចប់វគ្គ និងវិធីជ្រើសតាំងគណៈមេប្រយោគនៅតាមសហគ្រាស គ្រឹះស្ថាននានា
- ធ្វើទំនាក់ទំនង សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុននានាសំដៅជម្រុញការអនុវត្តន៍កាតព្វកិច្ចហ្វឹកហ្វឺនកូនជាងឲ្យធានាបាននូវនិរន្តរភាព និងគុណវុឌ្ឍិនៃការហ្វឹកហ្វឺនតាមមុខជំនាញនីមួយៗ
- ធ្វើអធិការកិច្ចលើការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងនៅតាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនទាំងអស់ដែលមានប្រើប្រាស់កម្មករ និយោជិតតាមចំនួនដូចមានចែងក្នុងច្បាប់ស្តីពីការងារ
- ណែនាំ និងជម្រុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងនៅតាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនដែលទើបបើកថ្មី
- សហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត-ដើម្បីគ្រប់គ្រង និងជម្រុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការងារ
- ពិនិត្យការចុះបញ្ជិកាលើកិច្ចសន្យាហ្វឹកហ្វឺនកូនជាង និងផ្តល់ទិដ្ឋាការលើបទបញ្ជាស្តីពីការហ្វឹកហ្វឺនកូនជាង
- ត្រួតពិនិត្យដំណើរការវគ្គហ្វឹកហ្វឺនកូនជាង ដើម្បីធានាគុណភាពនៃការហ្វឹកហ្វឺនសមស្របតាមកម្មវិធីដែលបានកំណត់
- ផ្តល់វិញ្ញាបនបត្រស្តីពីការហ្វឹកហ្វឺនកូនជាង និងប័ណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈដល់កូនជាងដែលបានហ្វឹកហ្វឺន និងបានឆ្លងកាត់ការប្រឡងបញ្ចប់វគ្គជាប់ជាស្ថាពរ
- គ្រប់គ្រងពន្ធអាករសម្រាប់ការហ្វឹកហ្វឺនកូនជាង ដូចមានចែងក្នុងច្បាប់ស្តីពីការងារ

- រៀបចំលិខិតបទដ្ឋានផ្សេងៗ ដើម្បីផាកពិន័យចំពោះសហគ្រាស គ្រឹះស្ថាន និងក្រុមហ៊ុនដែលពុំព្រមអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង
- រៀបចំឯកសារពាក់ព័ន្ធបញ្ជូនទៅតុលាការ ចំពោះសហគ្រាស គ្រឹះស្ថាន និងក្រុមហ៊ុនដែលពុំព្រមអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៦-ការិយាល័យមូលនិធិបង្កើតមុខរបរដោយខ្លួនឯង** មានភារកិច្ចៈ

- រៀបចំផែនការសកម្មភាពការងារ និងថវិកាប្រចាំឆ្នាំសម្រាប់ការផ្តល់ប្រាក់កម្ចី
- សម្របសម្រួលដល់ការរៀបចំ និងចងក្រងក្រុមដើម្បីផ្តល់ប្រាក់កម្ចីដល់អ្នកទទួលបានការបណ្តុះបណ្តាលក្នុងការប្រកបមុខរបរដោយខ្លួនឯង
- រៀបចំកិច្ចសន្យា និងការផ្តល់ប្រាក់កម្ចី ដល់ក្រុមដែលបានចងក្រងរួច
- រៀបចំបញ្ជីគណនេយ្យ និងធ្វើរបាយការណ៍ស្តីពីប្រាក់កម្ចី និងបង់ចូលត្រឡប់វិញ
- រៀបចំយន្តការសម្រាប់ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើសកម្មភាពប្រើប្រាស់ប្រាក់កម្ចីដែលបានផ្តល់ជូន
- ប្រមូលចងក្រងស្ថិតិក្រុមគោលដៅសិស្ស សិក្ខាកាមដែលប្រកបមុខរបរដោយខ្លួនឯងតាមរយៈមូលនិធិបង្កើតមុខរបរ
- រៀបចំកម្មវិធី និងឯកសារសម្រាប់ការប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងអង្គការផ្តល់ជំនួយលើមូលនិធិបង្កើតមុខរបរ
- រៀបចំផែនការសកម្មភាពការងារ និងគម្រោងថវិកាចំណាយប្រចាំឆ្នាំ
- សហការជាមួយគ្រឹះស្ថានសិក្សាដែលពាក់ព័ន្ធក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើតមុខរបរដោយខ្លួនឯង
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**៧-ការិយាល័យប្រឡង** មានភារកិច្ចៈ

- សិក្សាកែលម្អ និងរៀបចំប្រកាសស្តីពីបទបញ្ញានៃការប្រឡងជ្រើសរើស ការជ្រើសរើស និងការធ្វើតេស្តជ្រើសរើស
- សិក្សាកែលម្អ និងរៀបចំប្រកាសស្តីពីបទបញ្ញានៃការប្រឡងបញ្ចប់ការសិក្សា
- រៀបចំគម្រោងថវិកាសម្រាប់ដំណើរការប្រឡងជ្រើសរើស ការជ្រើសរើស និងប្រឡងបញ្ចប់ការសិក្សារបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- រៀបចំគម្រោងសម្ភារសម្រាប់ដំណើរការប្រឡងជ្រើសរើស ការជ្រើសរើស និងប្រឡងបញ្ចប់ការសិក្សារបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- កំណត់កាលបរិច្ឆេទប្រឡងជ្រើសរើស ការជ្រើសរើស តេស្តជ្រើសរើស និងប្រឡងបញ្ចប់ការសិក្សារបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រចាំឆ្នាំ
- រៀបចំលិខិតឧទ្ទេសនាមប្រឡងជ្រើសរើស ការជ្រើសរើស និងប្រឡងបញ្ចប់ការសិក្សារបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- សិក្សាគោលការណ៍ និងវិធានការប្រឡងជ្រើសរើស ការជ្រើសរើស តេស្តជ្រើសរើស និងប្រឡងបញ្ចប់ការសិក្សា ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច ដើម្បីធានាបាននូវគុណភាពបណ្តុះបណ្តាល
- សម្របសម្រួល និងដោះស្រាយរាល់ពាក្យបណ្តឹងរបស់បេក្ខជនក្នុងការប្រឡងជ្រើសរើស ការជ្រើសរើស តេស្តជ្រើសរើស និងប្រឡងបញ្ចប់ការសិក្សារបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ចូលរួមតាមដានកម្មវិធីការពារនិក្ខេបបទបញ្ចប់ការសិក្សារបស់ សិស្ស និស្សិត
- រៀបចំប្រកាសលទ្ធផលនៃការប្រឡងជ្រើសរើស ការជ្រើសរើស តេស្តជ្រើសរើស ប្រឡងបញ្ចប់ការសិក្សា និងការការពារនិក្ខេបបទ របស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកដ្ឋាន
- សហការការងារជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣**.- អង្គការលេខរបស់នាយកដ្ឋានបណ្តុះបណ្តាលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤**.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥**.- នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ:** ០៦៣/១៥ ក.ប/ប្រ.ក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥



**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០៦៤/១៥ **ក.ប**/ប្រ.ក

## ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
